# ជីវិត និងស្នាដៃរួមគ្នារបស់កសិករ

## យើងរួមគ្នាជំរុញអោយមានអ្នកអនុវត្ត បវស កាន់តែច្រើនឡើង




ដើម្បីជំរុញឱ្យមានអ្នកអនុវត្តប្រពន្ធ័ប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិ (ប.វ.ស) បានកាន់តែច្រើនថែមទៀត នៅដើមរដូវវស្សានេះ (ខែឧសភា និងមិថុនា ឆ្នាំ២០០៩) គំរោង **កាត់បន្ថយភាពក្រីក្រ សំរាប់កសិករធ្វើស្រែ តាមរយៈការជំរុញប្រពន្ធ័ចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព** **(PRS-EU)** បានជួយគាំទ្រទៅដល់បណ្តាញអភិវឌ្ឍន៍ឃុំ (កម្រង) តាមរយៈឱ្យពួកគាត់លើកជាគំរោងស្នើរសុំថវិការពីគំរោង ដោយមានការចូលរួមបដិភាគពីសហគមន៍។ ក្នុងចំណោមសម្មភាព ដ៏មានសារៈប្រយោជន៏ ទាំងនោះ យុទ្ធនាការផ្សព្វផ្សាយពី (ប.វ.ស) ជាសកម្មភាពមួយដែលពួកគាត់បានធ្វើចំនួន **១៨កម្រង ១៨យុទ្ធនាការ** ដែលមានអ្នកចូល រួមសរុប **៥៣៥នាក់ ស្ត្រី១១៩នាក់** ក្នុងស្រុកសំរោង និងបាទី (ខេត្តតាកែវ) ស្រុកបរសេដ្ឋ និងគងពិសី (ខេត្តកំពង់ស្ពឺ)។



ទិដ្ឋភាពស្រែ ប.វ.ស កំពង់លូតលាស់

## ១. មូលហេតុ

មូលហេតុដែលនាំឲ្យពួកគាត់ផ្តួចផ្តើមធ្វើយុទ្ធនាការនេះឡើងដោយសារ :

- ការអនុវត្តបច្ចេកទេសនេះពុំទាន់បានគ្រប់គ្នានៅក្នុងភូមិដោយកង្វះពត៌មានបច្ចេកទេស
- អ្នកដែលបានអនុវត្តកន្លងមកពុំមានឱកាសផ្សព្វផ្សាយពីបទពិសោធន៏របស់ខ្លួនអោយបានទូលំទូលាយទៅដល់អ្នកដទៃទៀតដែលរស់នៅឆ្ងាយពីផ្ទះរបស់ខ្លួន
- ការអនុវត្តប្រពន្ធ័ប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ មិនបានច្រើនបច្ចេកទេស ឬ ចំនុចមានន័យថាអ្នកដែលអនុវត្តភាគច្រើនយកតែ ៥ ទៅ ៦ចំនុចទៅធ្វើ ។

## ២. គោលបំណង

- បញ្ជូនសារស្តីពីបច្ចេកទេស ប.វ.ស ទៅដល់កសិករអ្នកធ្វើស្រែឲ្យបានយល់ដឹង កាន់តែទូលំទូលាយនិងច្បាស់លាស់ពីបច្ចេកទេសនេះថែមទៀត
- ជំរុញឲ្យមានអ្នកអនុវត្តបច្ចេកទេស ប.វ.ស បានកាន់តែច្រើនទៀតហើយតាមរយៈបច្ចេកទេសនេះពួកគាត់នឹង អាចបង្កើនផលិតកម្ម និងស្បៀងក្នុងគ្រួសាររបស់ខ្លួនបានច្រើនជាងមុន
- បង្កើនស្មារតី ឬការយល់ដឹងទាក់ទងនឹងផលវិបាកនៃការប្រើប្រាស់ថ្នាំពុល និងជីគីមី
- បង្កើនសាមគ្គីភាពនិងសហការក្នុងចំណោមកសិករនិងកសិករ កសិករនិងអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ពន្ធ័ ។

## ៣. វិធីសាស្ត្រនិងដំណើរការ

យុទ្ធនាការនេះប្រព្រឹត្តទៅដោយ មានរៀបចំជាពាក្យស្លោកទាក់ទងនឹង ប.វ.ស ដង្ហែរតាមភូមិមានរៀបចំថតជាខ្សែអាត់សំលេង ចូលគ្រប់ផ្លូវសំខាន់ៗដែលមាននៅក្នុងភូមិ ចុះផ្សព្វផ្សាយ ១៥ ទៅ ២០ នាទី ក្នុងភូមិ ដោយចុះជួបកសិករនៅក្នុងភូមិតាមផ្ទះ ដើម្បីចែកខិតប័ណ្ណ និងពន្យល់ដល់អ្នកភូមិ ជួយស្ទួងកសិករ និងធ្វើដំណើរយឺតៗ ។



**សកម្មភាពយុទ្ធនាការបច្ចេកទេស ប.វ.ស**

នៅពេលបញ្ចប់ ពួកគាត់បានធ្វើការឆ្លុះបញ្ចាំងពី ដំណើរការរៀបចំ ។ ជាលទ្ធផលពួកគាត់កត់សំគាល់ឃើញថា ការរៀបចំជាក្បួនដង្ហែនេះមាន ភាពប្រសើរជាងប្រជុំកិរិតភូមិព្រោះអ្នកភូមិបានទទួលពត៌មានទូលំទូលាយជាង ទោះជាពួកគាត់មិនបានចូលរួមជាមួយក៏ដោយ ក៏បានឮតាមសំលេងផ្សព្វផ្សាយដែរ ។ ជាក់ស្តែងក្នុងពេលដង្ហែនេះ ពេលចុះចែកខិតប័ណ្ណ មានអ្នកភូមិជាច្រើនបានសួរនាំពីរបៀបធ្វើ ប.វ.ស និងចំងល់ផ្សេងៗទៀត ហើយបាននិយាយថាពួកគាត់នឹងចាប់ផ្តើមអនុវត្តន៏ (អ្នកមិនធ្លាប់ធ្វើ) និងធ្វើអោយបានច្រើនថែមទៀត (អ្នកធ្លាប់ធ្វើ)ក្នុងឆ្នាំនេះ ។

## ៤. លទ្ធផល

តាមរយៈការរៀបចំយុទ្ធនាការនេះ បានលេចចេញនូវលទ្ធផលគួរឲ្យកត់សំគាល់មួយចំនួនគឺ

- **ទី១** បានដឹងកាន់តែច្បាស់អំពីការគិតរបស់កសិករពីមូលហេតុមិនទទួលយក បវស (គិតថាគ្មានទន្លល់ គ្មានគោជួលគេ រាំងពេក ទឹកច្រើន ស្រែជំរៅ ដីទួល ដីតិច សំណាបចាស់ ទើបមិនអាចធ្វើ ប.វ.ស បាន) តាមពិតមិនដូច្នេះទេ ប.វ.ស ជាវិធីសាស្ត្រងាយស្រួល និងសាញ្ញា
- **ទី២** កំណត់បានពី យុទ្ធសាស្ត្រសមក្នុងការជំរុញការធ្វើ ប.វ.ស នៅក្នុងរដូវវស្សានេះ
- **ទី៣** ធ្វើឲ្យកសិកររំលឹកឡើងវិញពីបច្ចេកទេស ប.វ.ស មានអ្នកយល់និងធ្វើ បវស បានច្រើនជាងមុន ដែលភាគច្រើនគាត់ស្ទូងសំណាបខ្ចី ស្ទូងរង្វើល ប្រើពូជតិចជាងមុន និងប្រើជីធម្មជាតិជាដើម
- **ទី៤** អាជ្ញាធរមូលដ្ឋាន បានឲ្យតម្លៃជាខ្លាំង ដោយឈានមុខគេ ក្នុងការអនុវត្តន៍ និងជួយជំរុញកសិករបន្ថែម។

**ហ៊ឹម នឿន**